00818892

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 06 / 2012
ម៉ោង (Time/Heure): 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E138/1/7/13

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** មេធាវីការពារក្ដីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ
ភាគីទាំងអស់នៃសំណុំរឿង ០០២
លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**កាលបរិច្ឆេទ:** ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង [signature]

**ចម្លងជូន:** មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង; អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ

**កម្មវត្ថុ:** ការកំណត់កាលបរិច្ឆេទនៃការវាយតម្លៃលើបញ្ហាកាយសម្បទានិងសតិបញ្ញាស្មារតីឡើងវិញ និងសវនាការស្ដីពីបញ្ហាកាយសម្បទានិងសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ

កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានការវាយតម្លៃជាឯកច្ឆន្ទរបស់អ្នកជំនាញវេជ្ជសាស្ត្រចំនួន ៥ រូប ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះ បានសម្រេចថាជនជាប់ចោទ អៀង ធីរិទ្ធ បានទទួលរងនូវជំងឺចុះខ្សោយសតិបញ្ញាស្មារតីជាបន្តបន្ទាប់ (អាចជា ជំងឺបាត់ការចងចាំ) ដែលធ្វើឲ្យជនជាប់ចោទមិនមានសមត្ថភាពកាយសម្បទានិងសតិបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ដោយហេតុថាកិច្ចដំណើរការនីតិវិធីចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានផ្អាក និងដោយមិនមាននូវហេតុផលសមស្របណាមួយដើម្បីបន្តកិច្ចដំណើរការនីតិវិធីចំពោះរូបគាត់ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យដោះលែងជនជាប់ចោទជាបន្ទាន់ (ឯកសារE138)។ បន្ទាប់ពីមានបណ្ដឹងសាទុក្ខរបស់សហព្រះ-

រាជអាជ្ញាលើសេចក្តីសម្រេចស្តីពីការដោះលែងនេះ អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក (អ.ជ.ត.ក) កាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ បានសម្រេចថា "អ.វ.ត.ក ត្រូវប្រើឱ្យអស់នូវរាល់វិធានការដែលមាន ដែលអាចជួយឱ្យជនជាប់ចោទ អៀង ធីរិទ្ធ មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ" និងបានបញ្ជូនបញ្ហានេះត្រឡប់មកអង្គជំនុំជម្រះសាលាដំបូងវិញ (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ៣៦-៣៨ ឯកសារ E138/1/7)។

បន្ទាប់ពីបានទទួលសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលស្នើសុំឱ្យរៀបចំអនុសាសន៍សមស្របនានាតាមក្បួនវេជ្ជសាស្ត្រ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ អ.ជ.ត.ក អ្នកជំនាញវេជ្ជសាស្ត្របានលើកឡើងនូវវិធានការចំនួន ០២ ដែលអាចធ្វើឱ្យមុខងារសតិបញ្ញាស្មារតីរបស់លោកស្រី អៀង ធីរិទ្ធ មានភាពល្អប្រសើរឡើងវិញ។ វិធានការទាំងនេះមានជាអាទិ៍ (១) ការកាត់បន្ថយបន្តិចម្តងនូវឱសថ Bromazepam (ឬ Lexomil) និង (២) ការព្យាបាលដោយប្រើឱសថ Rivastigmine។ ការព្យាបាលតាមរយៈការលើកកម្ពស់សតិបញ្ញាស្មារតី ក៏ត្រូវបានណែនាំផងដែរ ដើម្បីបំពេញបន្ថែមដល់ការព្យាបាលដោយឱសថនេះ បើទោះជាមានការកត់សម្គាល់ថា ពុំមានភស្តុតាងសំខាន់ណាមួយបង្ហាញថា ការព្យាបាលដោយចលនាតែមួយមុខអាចកែប្រែការធ្លាក់ចុះផ្នែកសតិបញ្ញាស្មារតីបានឡើយ (របាយការណ៍ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ តបតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង, ឯកសារ E138/1/7/4, កថាខណ្ឌ ៨)។ អ្នកជំនាញវេជ្ជ-សាស្ត្របានគូសបញ្ជាក់ថាការព្យាបាលដោយឱសថ Rivastigmine ចំនួន ១៨ សប្តាហ៍ និងការព្យាបាលដើម្បីលើកកម្ពស់សតិបញ្ញាស្មារតីចំនួន ០៣ ខែ នឹងគ្រប់គ្រាន់សម្រាប់ផលប្រយោជន៍ផ្សេងៗ ដែលអាចនឹងលេចចេញឡើង (ឯកសារ E138/1/7/9 និងឯកសារ E138/1/7/4)។

គ្រូពេទ្យព្យាបាលរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានរាយការណ៍ថាឱសថ Lexomil ត្រូវបានកាត់បន្ថយក្នុងកម្រិតមួយភាគបួនជារៀងរាល់សប្តាហ៍ចាប់ពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ និងបានបញ្ឈប់ទាំងស្រុងនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ E12/68/1.1)។ ការព្យាបាលដោយឱសថ Rivastigmine បានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ ហើយជនជាប់ចោទ អៀង ធីរិទ្ធ នឹងទទួលការព្យាបាលដោយឱសថនេះគ្រប់ចំនួន ១៨ សប្តាហ៍នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (ឬប្រហែលជាក្នុងអំឡុងពេលនោះ)។ អ្នកជំនាញឯកទេសព្យាបាលដោយចលនាមួយរូបបានបណ្តុះបណ្តាលគិលានុបដ្ឋាយិកាចំនួន ០២ រូប កាលពីថ្ងៃទី០៣-០៤ ខែ ឧសភា ឆ្នាំ ២០១២។ កម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតីសម្រាប់ជនជាប់ចោទ អៀង ធីរិទ្ធ បានចាប់ផ្តើម

នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ និងដំណើរការគម្រប់ចំនួន ០៣ ខែ គិតត្រឹមថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ (ឯកសារE138/1/7/12)។

បញ្ហានាពេលបច្ចុប្បន្នគឺទាក់ទងទៅនឹងការបន្តការឃុំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ ហើយអង្គជំនុំជម្រះត្រូវតែសម្រេចជាមុន អំពីផលវិបាកដែលបណ្តាលមកពីស្ថានភាពសុខភាពរបស់គាត់ទៅលើកិច្ចដំណើរការនីតិវិធី និងការឃុំខ្លួនបណ្តោះអាសន្ននេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវាយតម្លៃជាថ្មីភ្លាមៗ អំពីសមត្ថភាពកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីផុតកំណត់នូវរយៈពេលនៃការអនុវត្តនូវវិធានការផ្សេងៗ ដែលបានកំណត់នៅក្នុង សេចក្តីសម្រេចរបស់ អ.ជ.ត.ក (ឯកសារ E138/1/7, កថាខណ្ឌ ៥០)។ ហេតុដូច្នេះ សវនាការពាក់ព័ន្ធនឹងរបាយការណ៍វេជ្ជសាស្ត្រ និងការឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវបានកំណត់ពេលធ្វើនៅចុងខែ សីហា ឆ្នាំ ២០១២ ខាងមុខនេះ។ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងម្តងទៀតនូវអ្នកជំនាញវេជ្ជសាស្ត្រដែលអាចមានលទ្ធភាពធ្វើការពិនិត្យបាន (ដែលមានដូចជា៖ វេជ្ជបណ្ឌិត John CAMPBELL, វេជ្ជបណ្ឌិត ហួត លីនណា, និងវេជ្ជបណ្ឌិត Seena FAZEL) ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃទៅលើស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងគោលបំណងដើម្បីបញ្ចប់នូវកិច្ចការជំនាញដែលបានចាត់តាំងពីពេលមុន និងដើម្បីធ្វើការសម្រេចរួមគ្នា ថាតើវិធានការដែលបានអនុវត្តចាប់តាំងពីបានទទួលការព្យាបាលមកនោះ បានធ្វើឱ្យសមត្ថភាពសតិ-បញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានល្អប្រសើរក្នុងកម្រិតមួយដែលជនជាប់ចោទអាចមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការបានដែរឬទេ។ ដោយសារការវាយតម្លៃឡើងវិញនិងវត្តមានរបស់អ្នកជំនាញមានកម្រិត ទើបអង្គជំនុំជម្រះសាលាដំបូងស្នើសុំឱ្យអ្នកជំនាញផ្តល់របាយការណ៍សង្ខេបរួមមួយជាលាយលក្ខណ៍អក្សរ ឱ្យបានមុនពេលចាប់ផ្តើមសវនាការក្នុងគោលបំណងដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។

ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមកំណត់កាលបរិច្ឆេទនៃការវាយតម្លៃលើបញ្ហាកាយសម្បទានិងសតិបញ្ញាស្មារតីឡើងវិញ និងសវនាការលើបញ្ហាកាយសម្បទានិងសតិបញ្ញាស្មារតីដូចខាងក្រោមនេះ៖

ថ្ងៃទី ២៧-២៨ ខែ សីហា ឆ្នាំ ២០១២៖ ការវាយតម្លៃឡើងវិញអំពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ពីសំណាក់អ្នកជំនាញវេជ្ជសាស្ត្រ។

ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២៖ ការបញ្ចប់សេចក្តីសង្ខេបនៃរបាយការណ៍របស់អ្នកជំនាញ ដែលត្រូវប្រគល់មកអង្គជំនុំជម្រះសាលាដំបូង និងភាគីពាក់ព័ន្ធ ។

ថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១២៖ សវនាការដើម្បីបង្ហាញរបកគំហើញរបស់អ្នកជំនាញ និងការពិភាក្សាក្នុងសវនាការអំពីរបកគំហើញទាំងនេះ ពីសំ-ណាក់មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ វេជ្ជបណ្ឌិត FAZEL ត្រូវបានជ្រើសតាំងឲ្យផ្តល់សក្ខីកម្មជំនួសមុខឲ្យអ្នកជំនាញវេជ្ជសាស្ត្រទាំងអស់ ហើយ សាស្ត្រាចារ្យ Campbell និងវេជ្ជបណ្ឌិត ហួត លីនណា អាចនឹងមានវត្តមានដើម្បីឆ្លើយសំណួរ ប្រសិនបើចាំបាច់។

ជនជាប់ចោទ ខៀវ សំផន នួន ជា និង អៀង សារី មិនតម្រូវឲ្យមានវត្តមានក្នុងអំឡុងពេលសវនាការ នេះទេ។ ប៉ុន្តែ ដោយហេតុថាជនជាប់ចោទ អៀង សារី ជាស្វាមីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និងដោយសារមូលហេតុផ្ទាល់ខ្លួន ជនជាប់ចោទ អៀង សារី អាចស្នើសុំចូលរួមសវនាការនេះបាន ប្រសិនបើគាត់មានបំណងធ្វើដូច្នេះ។ ប្រសិនបើមេធាវីការពារក្តី អៀង សារី មានវត្តមានក្នុងសវនាការនេះជាមួយនឹងកូនក្តីរបស់ខ្លួន អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានណាមួយ ក្នុងអំឡុងពេលសវនាការនេះឡើយ។

ដូចដែលបានកំណត់នៅក្នុងដីកាកំណត់កាលបរិច្ឆេទកន្លងមក អង្គជំនុំជម្រះសាលាដំបូងនឹងបន្តធ្វើសវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ក្នុងអំឡុងថ្ងៃទី២៧-២៩ ខែ សីហា ឆ្នាំ ២០១២ ។ ប៉ុន្តែ អង្គជំនុំជម្រះនឹងធ្វើសវនាការលើបញ្ហាកាយសម្បទានិងសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១២ ។